002/19-09-2007-ECCC/TC
E1/227

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 28 / 08 / 2013
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**សាធារណៈ**

# សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

# ថ្ងៃអង្គារ៍ ទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣

# សវនាការលើអង្គសេចក្តី-ថ្ងៃ ២១៤

រៀបចំដោយ: **សែ កុលវុឌ្ឍី** និង **Roger PHILLIPS**

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សាខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោកស្រី Faiza ZOUAKRI, លោក Roger PHILLIPS |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង, លោក Dale LYSAK, លោក William SMITH |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Victor KOPPE |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Elisabeth SIMONNEAU-FORT, លោក ពេជ អង្គ, លោក វ៉ែន ពៅ, លោកស្រី ស៊ិន សុវន, លោកស្រី ជេត វណ្ណលី, លោក ហុង គីមសួន, លោកស្រី Beini YE |

| | |
|---|---|
| សាក្សី/ដើមបណ្ដឹង៖ លោក ស សារិន (TCCP-186) | |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ិច អារុណា, លោកស្រី ស្វ សុធារី | |
| ផ្សេងៗ៖ កញ្ញា ឈុន ដានីន, កញ្ញា Paola ROBOTTI, លោក Matthew CAMERON | |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ | ចាប់ផ្ដើមម៉ោង៖ ០៩.០៥ | បញ្ចប់ម៉ោង៖ ១៥.២៥ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.៤៥ | បញ្ចប់ម៉ោង៖ ១១.១០ |
| សម្រាកអាហារថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១២.00 | បញ្ចប់ម៉ោង៖ ១៥.០៥ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ គ្មាន | បញ្ចប់ម៉ោង៖ គ្មាន |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០២ ម៉ោង និង ៥០ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| សង្ខេបអំពីកិច្ចដំណើរការនីតិវិធី | អង្គជំនុំជម្រះ | ០៩.០៥ | ០៩.១០ |
| សំណើសុំកោះហៅសាក្សីបន្ថែម ទាក់ទងនឹងហេតុការណ៍នៅទួលពោធិជ្រៃ (E292/3) និង សេចក្ដីសន្និដ្ឋានផ្ទាល់មាត់របស់មេធាវីការពារក្ដី នួន ជា ទាក់ទងនឹងសំណើសុំសាក្សីបន្ថែម | សហព្រះរាជអាជ្ញា | ០៩.១០<br>០៩.១៩ | ០៩.១០<br>០៩.២២ |
| | មេធាវីនាំមុខ | ០៩.១១ | ០៩.១១ |
| | មេធាវីការពារក្ដី នួន ជា | ០៩.១២ | ០៩.១៧ |
| | មេធាវីការពារក្ដី ខៀវ សំផន | ០៩.១៧ | ០៩.១៩ |
| | អង្គជំនុំជម្រះ | ១៥.០៩ | ១៥.១០ |
| សំណើសុំរបស់សហព្រះរាជអាជ្ញាឲ្យអង្គជំនុំជម្រះពិចារណាឡើងវិញលើសេចក្ដីសម្រេចមិនកោះហៅដើមបណ្ដឹង ស សារិន មកផ្ដល់សក្ខីកម្ម (E293/1) | មេធាវីនាំមុខ | ០៩.២៤<br>០៩.៥៥<br>១០.២១<br>១១.១២ | ០៩.៤៤<br>០៩.៥៦<br>១០.២៤<br>១១.១៣ |
| | មេធាវីការពារក្ដី នួន ជា | ០៩.៤៤<br>១០.១៣ | ០៩.៤៦<br>១០.១៤ |
| | មេធាវីការពារក្ដី ខៀវ សំផន | ០៩.៤៦<br>១០.០៩ | ០៩.៥៤<br>១០.១១ |

| | | | |
|---|---|---|---|
| | សហព្រះរាជអាជ្ញា | ០៩.៥៦ | ១០.០៩ |
| | | ១០.១១ | ១០.១២ |
| | | ១០.១៦ | ១០.១៨ |
| | អង្គជំនុំជម្រះ | ១០.១៨ | ១០.២១ |
| | | ១០.២៤ | ១០.២៧ |
| | | ១០.៣៣ | ១០.៤២ |
| | | ១១.១១ | ១១.១២ |
| | | ១៥.១០ | ១៥.១១ |
| សំណើសុំរបស់សហព្រះរាជអាជ្ញាឱ្យធ្វើសេចក្តីសន្និដ្ឋានផ្ទុយប្រឆាំងនឹងជនជាប់ចោទ ក្នុងករណីជនជាប់ចោទមិនឆ្លើយតបទៅនឹងសំណួរ | សហព្រះរាជអាជ្ញា | ១១.១៤ | ១១.១៦ |
| | មេធាវីនាំមុខ | ១១.១៨ | ១១.១៩ |
| | មេធាវីការពារក្តី នួន ជា | ១១.២២ | ១១.២៥ |
| | មេធាវីការពារក្តី ខៀវ សំផន | ១១.២៥ | ១១.២៧ |
| | អង្គជំនុំជម្រះ | ១៥.១៥ | ១៥.១៦ |
| សំណើសុំរបស់សហព្រះរាជអាជ្ញាស្នើឱ្យអង្គជំនុំជម្រះចេញសេចក្តីសម្រេចលើការទទួលយកឯកសារឱ្យបានមុនពេលបញ្ចប់សវនាការលើភស្តុតាង | សហព្រះរាជអាជ្ញា | ១១.១៦ | ១១.១៨ |
| | មេធាវីនាំមុខ | ១១.១៩ | ១១.២០ |
| | មេធាវីការពារក្តី នួន ជា | ១១.២០ | ១១.២២ |
| | មេធាវីការពារក្តី ខៀវ សំផន | ១១.២៧ | ១១.២៩ |
| | អង្គជំនុំជម្រះ | ១៥.១៧ | ១៥.១៨ |
| | | ១៥.២១ | ១៥.២២ |
| សំណើសុំកោះហៅសាក្សីដែលពាក់ព័ន្ធនឹងគោលនយោបាយដែលត្រូវបានចោទប្រកាន់ក្នុងការវាយប្រហារមន្ត្រីសាធារណរដ្ឋខ្មែរ | មេធាវីការពារក្តី នួន ជា | ១១.៣១ | ១១.៣៧ |
| | | ១១.៤៦ | ១១.៤៨ |
| | សហព្រះរាជអាជ្ញា | ១១.៣៧ | ១១.៤៤ |
| | មេធាវីនាំមុខ | ១១.៤៤ | ១១.៤៦ |
| | អង្គជំនុំជម្រះ | ១៥.១១ | ១៥.១៣ |
| សំណើសុំរបស់មេធាវីការពារក្តី ខៀវ សំផន អំពីព័ត៌មានទាក់ទងនឹងសាក្សី នូ ម៉ុក | សហព្រះរាជអាជ្ញា | ១១.៥២ | ១១.៥៤ |
| | មេធាវីនាំមុខ | ១១.៥៤ | ១១.៥៥ |
| | មេធាវីការពារក្តី ខៀវ សំផន | ១១.៥៥ | ១១.៥៩ |
| | អង្គជំនុំជម្រះ | ១៥.១៣ | ១៥.១៥ |

| | | | |
|---|---|---|---|
| សំណើសុំរបស់មេធាវីការពារក្ដី នួន ជា ឱ្យទទួលយកភស្ដុតាងថ្មី, កោះហៅ Rob Lemkin និងស្នើបសួរបន្ថែម | អង្គជំនុំជម្រះ | ១៥.១៦ | ១៥.១៧ |
| សេចក្ដីសម្រេចអំពីកាលបរិច្ឆេទនៃការដាក់សារណាបញ្ចប់ និងការធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល | អង្គជំនុំជម្រះ | ១៥.១៨ | ១៥.២៣ |
| សេចក្ដីសម្រេចពីចំនួនទំព័រនៃសារណាបញ្ចប់ការពិភាក្សាដេញដោលដែលទាក់ទងនឹងសេចក្ដីសម្រេចលើភស្ដុតាងបន្ថែមដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះ | អង្គជំនុំជម្រះ | ១៥.២២ | ១៥.២៣ |

**សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ**

ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនដែលនៅពីក្រោមសាលសវនាការនេះតាមវិធាន ៨១.៥ និង ផ្អែកតាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះលើបញ្ហាសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៣ (ឯកសារ E256/5) ។

**សេចក្ដីសង្ខេបនៃដំណើរការនីតិវិធី**

អង្គជំនុំជម្រះបានជូនដំណឹងទៅភាគីអំពីបញ្ហាដែលជាកម្មវត្ថុនៃការពិភាក្សានៅក្នុងថ្ងៃនេះ។ អង្គជំនុំជម្រះក៏បានជូនដំណឹងទៅភាគីផងដែរថា សំណើលើកទី២របស់ក្រុមមេធាវីការពារក្ដី នួន ជា និងសំណើសុំចុងក្រោយឱ្យកោះហៅសាក្សី TCW-223 ដែលបានដាក់នៅថ្ងៃចន្ទ ទី ២២ ខែ កក្កដា ឆ្នាំ ២០១៣ និងបញ្ចូលទៅក្នុងបញ្ជីដែលមិនទាន់សម្រេច ហើយអង្គជំនុំជម្រះនិងចេញសេចក្ដីសម្រេចអំពីបញ្ហានេះនៅក្នុងសេចក្ដីសម្រេចចុងក្រោយលើបញ្ហាសាក្សី។

**សំណើសុំកោះហៅសាក្សីបន្ថែម ទាក់ទងនឹងហេតុការណ៍នៅទួលពោធិជ្រៃ (E292/3) និងសេចក្ដីសន្និដ្ឋានផ្ទាល់មាត់ របស់មេធាវីការពារក្ដី នួន ជា ទាក់ទង នឹងសំណើសុំសាក្សីបន្ថែម**

នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៣ សហព្រះរាជអាជ្ញាបានស្នើឱ្យអង្គជំនុំជម្រះស្ដាប់សក្ខីកម្មសាក្សីពីរនាក់បន្ថែមទៀត គឺសាក្សីដែលមានរហស្សនាម TCW-644 និងដើមបណ្ដឹងរដ្ឋប្បវេណីថ្មីនៅក្នុងសំណុំរឿង ០០៤ ទាក់ទងនឹងហេតុការណ៍នៅទួលពោធិជ្រៃ។ មេធាវីការពារក្ដី នួន ជា បានស្នើសុំឱ្យកោះហៅ

សាក្សីបន្ថែមមួយចំនួនដូចជា TCW-802, TCW-803 និង លោក Rob LEMKIN (TCW-382)។ សហព្រះរាជអាជ្ញា មេធាវីនាំមុខ មេធាវីការពារក្តី នួន ជា និងមេធាវីការពារក្តី ខៀវ សំផន បានធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ពីសំណើសុំនេះ។ អង្គជំនុំជម្រះបានបដិសេធចំពោះសំណើសុំនេះ (សូមមើលសេចក្តីសម្រេចផ្ទាល់មាត់ខាងក្រោម)។

**<u>សំណើសុំរបស់សហព្រះរាជអាជ្ញាឱ្យអង្គជំនុំជម្រះពិចារណាឡើងវិញលើសេចក្តីសម្រេចមិនកោះហៅដើមបណ្តឹងរដ្ឋប្បវេណី ស សារិន មកផ្តល់សក្ខីកម្ម</u>** (E293/1)

មេធាវីនាំមុខនិងសហព្រះរាជអាជ្ញាបានធ្វើសេចក្តីសន្និដ្ឋានទាក់ទងនឹងសំណើសុំឱ្យអង្គជំនុំជម្រះពិចារណាឡើងវិញអំពីសេចក្តីសម្រេចរបស់ខ្លួនដែលបានបដិសេធមិនកោះហៅដើមបណ្តឹង ស សារិន (TCCP-186)។ នៅក្នុងអំឡុងពេលនៃការពិភាក្សាគ្នា អង្គជំនុំជម្រះបានកោះហៅលោក ស សារិន និងបានតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ទាក់ទងនឹងការបដិសេធមិនផ្តល់សក្ខីកម្មដល់តុលាការក្នុងករណីដែលមិនមានវិធានការការពារដែលមិនអាចផ្តល់បានដោយតុលាការនោះ។ លោក ស សារិន បានបញ្ជាក់ថា គាត់មិនមានបំណងក្នុងការផ្តល់សក្ខីកម្មដល់តុលាការទេ ប្រសិនបើតុលាការមិនអាចផ្តល់វិធានការការពារតាមការស្នើសុំរបស់គាត់ដូចបានបង្ហាញពីលើកមុន។ អង្គជំនុំជម្រះបានបដិសេធនូវសំណើសុំនេះ (សូមមើលសេចក្តីសម្រេចផ្ទាល់មាត់ខាងក្រោម)។

**<u>សំណើសុំរបស់សហព្រះរាជអាជ្ញាឱ្យធ្វើសេចក្តីសន្និដ្ឋានផ្ទុយប្រឆាំងនឹងជនជាប់ចោទក្នុងករណីជនជាប់ចោទមិនឆ្លើយតបទៅនឹងសំណួរ</u>**

សហព្រះរាជអាជ្ញា មេធាវីនាំមុខ មេធាវីការពារក្តី នួន ជា និងមេធាវីការពារក្តី ខៀវ សំផន បានធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ទាក់ទងនឹងការព្រមានដល់ជនជាប់ចោទនូវការសន្និដ្ឋានផ្ទុយក្នុងករណីដែលជនជាប់ចោទមិនព្រមផ្តល់សក្ខីកម្ម។ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យដាក់នូវប្រធានបទមួយចំនួន និង ការតាំងសំណួរទៅជនជាប់ចោទ ដែលគួរត្រូវបានណែនាំទៅជនជាប់ចោទ ដើម្បីឱ្យពួកគេសម្រេចចិត្តក្នុងការផ្តល់សក្ខីកម្ម។ អង្គជំនុំជម្រះបានបដិសេធនូវសំណើសុំនេះ (សូមមើលសេចក្តីសម្រេចផ្ទាល់មាត់ខាងក្រោម)។

**<u>សំណើសុំរបស់សហព្រះរាជអាជ្ញាស្នើឱ្យអង្គជំនុំជម្រះចេញសេចក្តីសម្រេចលើការទទួលយកឯកសារឱ្យបានមុនពេលបញ្ចប់ សវនាការលើភស្តុតាង</u>**

សហព្រះរាជអាជ្ញា មេធាវីនាំមុខ មេធាវីការពារក្តី នួន ជា និងមេធាវីការពារក្តី ខៀវ សំផន បានធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ទាក់ទងនឹងសំណើសុំឱ្យអង្គជំនុំជម្រះចេញសេចក្តីសម្រេចទទួលយកឯកសារមួយ

ចំនួន មុនពេលបញ្ចប់សវនាការលើភស្តុតាង។

អង្គជំនុំជម្រះបានជូនដំណឹងទៅភាគីថា អង្គជំនុំជម្រះនឹងចេញនូវសេចក្តីសម្រេចបដិសេធភាពអាចទទួលបាននៃកំណត់ហេតុស្តាប់សាក្សី ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងប្រតិចារឹកនៅក្នុងសំណុំរឿង០០១ ដែលស្នើឡើងដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសេចក្តីសម្រេចទី៣ ស្តីពីការជំទាស់ទៅនឹងឯកសារដែលបានស្នើឱ្យដាក់នៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុងពេលឆាប់ៗខាងមុខ។ សេចក្តីសម្រេចទាំងពីរនេះ នឹងមានភ្ជាប់ឧបសម្ព័ន្ធផងដែរ។ ឯកសារទាំងអស់ដែលត្រូវបានទទួលយកដែលជាលទ្ធផលនៃសេចក្តីសម្រេចនេះ នឹងមានលេខ E3។

អង្គជំនុំជម្រះក៏បានជូនដំណឹងទៅភាគីផងដែរថា នៅក្នុងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីររបស់ខ្លួន (ឯកសារ E284) អង្គជំនុំជម្រះបានសម្រេចពីវិសាលភាពនៃអង្គហេតុដែល អង្គជំនុំជម្រះត្រូវធ្វើការពិចារណានៅក្នុងសំណុំរឿង០០២/០១។ សេចក្តីសម្រេចនេះ ត្រូវបានប្តឹងសាទុក្ខដោយសហព្រះរាជអាជ្ញា និង នួន ជា។ ដោយរង់ចាំលទ្ធផលនៃបណ្តឹងសាទុក្ខ និងដើម្បីជៀសវាងការប៉ះពាល់ដែលអាចមានចំពោះភាគីទាំងអស់។ អង្គជំនុំជម្រះសាលាដំបូងនឹងមិនចេញសេចក្តីសម្រេចស្ថាពររបស់ខ្លួនអំពីសាក្សី សាក្សីអ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវស្តាប់នៅក្នុងសំណុំរឿង០០២/០១នោះទេ។ ហើយសេចក្តីសម្រេចនេះនឹងត្រូវយកទៅដាក់បញ្ចូលនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះជាជាងចេញសេចក្តីសម្រេចដាច់ដោយឡែកនៅពេលខាងមុខនេះ។ អង្គជំនុំជម្រះកត់សម្គាល់ថាភាគីទាំងអស់នេះទទួលបាននូវឯកសារចម្លងនៃឧបសម្ព័ន្ធទាំងអស់នៃសេចក្តីសម្រេចនេះរួចរាល់ហើយ ហើយព័ត៌មានដែលមាននៅក្នុងឧបសម្ព័ន្ធទាំងអស់នោះមិនមានការកែប្រែនោះទេ។

**<u>សំណើសុំឲ្យកោះហៅសាក្សីដែលពាក់ព័ន្ធនឹងគោលនយោបាយដែលត្រូវបានចោទប្រកាន់ក្នុងការវាយប្រហារមន្ត្រីសាធារណរដ្ឋខ្មែរ</u>**

មេធាវីការពារក្តី នួន ជា សហព្រះរាជអាជ្ញា និងមេធាវីនាំមុខ បានធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ទាក់ទងនឹងសំណើសុំឱ្យកោះហៅសាក្សីថ្មីជាង១០០នាក់ដែលបានឆ្លើយទាក់ទងនឹងគោលដៅនៃមន្ត្រីសាធារណរដ្ឋខ្មែរ។ អង្គជំនុំជម្រះបានបដិសេធសំណើសុំនេះ (សូមមើលសេចក្តីសម្រេចផ្ទាល់មាត់ខាងក្រោម)។

**<u>សំណើសុំរបស់មេធាវីការពារក្តី ខៀវ សំផន អំពីព័ត៌មានទាក់ទងនឹងសាក្សី នូ ម៉ុក</u>**

សហព្រះរាជអាជ្ញា មេធាវីនាំមុខ និងមេធាវីការពារក្ដី ខៀវ សំផន បានធ្វើសេចក្ដីសន្និដ្ឋានផ្ទាល់មាត់ទាក់ទងនឹងសំណើសុំព័ត៌មានទាក់ទងនឹងសាក្សី នូ ម៉ុក។ អង្គជំនុំជម្រះបានបដិសេធសំណើសុំនេះ និងបានបង្គាប់ឱ្យអង្គភាពគាំពារសាក្សីនិងអ្នកជំនាញផ្ដល់ព័ត៌មានជាទម្រង់របាយការណ៍ផ្លូវការមកអង្គជំនុំជម្រះក្នុងរយៈពេលពីរសប្ដាហ៍ (សូមមើលសេចក្ដីសម្រេចផ្ទាល់មាត់ខាងក្រោម)។

**<u>សំណើសុំរបស់មេធាវីការពារក្ដី នួន ជា ឱ្យទទួលយកភស្តុតាងថ្មី, កោះហៅ Rob Lemkin និងការស៊ើបសួរបន្ថែម</u>**

អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីថា អង្គជំនុំជម្រះនឹងចេញសេចក្ដីសម្រេចរបស់ខ្លួនលើសំណើនេះ នៅថ្ងៃអង្គារ៍ ទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ឬនៅថ្ងៃពុធ ទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣ ដោយបដិសេធសំណើសុំនេះទាំងមូល ដោយផ្អែកលើសំអាងហេតុដោយមានរៀបរាប់នៅក្នុងសេចក្ដីសម្រេចនោះ។

**<u>សេចក្ដីសម្រេចអំពីកាលបរិច្ឆេទនៃការដាក់សារណាបញ្ចប់ និងការធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល</u>**

អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីថា អង្គជំនុំជម្រះសាលាដំបូងប្រកាសថា សវនាការលើភស្តុតាងនៅក្នុងសំណុំរឿង០០២/០១ មិនទាន់បិទបញ្ចប់ជាផ្លូវការនៅឡើយទេ រហូតដល់អង្គជំនុំជម្រះតុលាការកំពូលចេញសេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា និងមេធាវីការពារក្ដី នួន ជា ប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីរស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង០០២ (E284)។ ទោះជាយ៉ាងនេះក្ដី ក្នុងរយៈពេលរង់ចាំសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល អង្គជំនុំជម្រះសាលាដំបូងសូមប្រកាសកាលបរិច្ឆេទបណ្ដោះអាសន្នរបស់ខ្លួនដូចខាងក្រោម ដែលអង្គជំនុំជម្រះនឹងផ្ដល់គោលការណ៍ណែនាំបន្ថែមទៀតលើចំណុចនេះ នៅពេលមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលនាពេលខាងមុខ (សូមមើលសេចក្ដីសម្រេចផ្ទាល់មាត់ខាងក្រោម)។

**<u>សេចក្ដីសម្រេចពីចំនួនទំព័រនៃសារណា បញ្ចប់ការពិភាក្សាដេញដោលដែលទាក់ទងនឹងសេចក្ដីសម្រេចលើភស្តុតាងបន្ថែមដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះ</u>**

អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីថាពួកគេនឹងទទួលបានចំនួនទំព័របន្ថែមទៀតដើម្បីឆ្លើយតបចំពោះភស្តុតាង ឬឯកសារបន្ថែមដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង អនុលោមតាមសេចក្ដីសម្រេចស្ដាពរលើភស្តុតាងរបស់អង្គជំនុំជម្រះ (សូមមើលសេចក្ដីសម្រេចផ្ទាល់មាត់ខាងក្រោម)។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>**

**<u>ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖</u>**

- **សំណើសុំកោះហៅសាក្សីបន្ថែម ទាក់ទងនឹងហេតុការណ៍នៅទួលពោធិ៍ជ្រៃ (E292/3) និងសេចក្ដីសន្និដ្ឋានផ្ទាល់មាត់ របស់មេធាវីការពារក្ដី នួន ជា ទាក់ទង នឹងសំណើសុំសាក្សីបន្ថែម**

  នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៣ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យអង្គជំនុំជម្រះស្ដាប់សក្ខីកម្មសាក្សីបន្ថែមចំនួនពីររូប ទាក់ទងនឹងទួលពោធិ៍ជ្រៃ គឺ TCW-644 និងដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤។ មេធាវីការពារក្ដី នួន ជា មិនជំទាស់ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញានេះទេ និងបានស្នើសុំបន្ថែមឱ្យអង្គជំនុំជម្រះកោះហៅសាក្សី TCW-802, TCW-803 និងលោក Rob LEMKIN អង្គជំនុំជម្រះយល់ឃើញថា ភស្តុតាងរបស់សាក្សី TCW-644, TCW-802, TCW-803 និងដើមបណ្ដឹងរដ្ឋប្បវេណីថ្មីនេះមាន លក្ខណៈច្រំដែលទៅនឹងភស្តុតាងដទៃ និងមិនបាននាំដល់ការស្វែងរកការពិតទេ។ ហេតុដូច្នេះសំណើទាំងនេះត្រូវបដិសេធចោល។ សំណើសុំឱ្យកោះហៅលោក Rob LEMKIN ត្រូវបានសម្រេច នៅក្នុងសេចក្ដីសម្រេច ដោយឡែកដែលនឹងចេញនៅក្នុងពេលឆាប់ៗខាងមុខនេះ។

- **សំណើសុំរបស់សហព្រះរាជអាជ្ញាឱ្យអង្គជំនុំជម្រះពិចារណាឡើងវិញលើសេចក្ដីសម្រេចមិនកោះហៅដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន មកផ្ដល់សក្ខីកម្ម** (E293/1)

  បើទោះបីជាសំណើនេះត្រូវបានចាត់ទុកថាជាសំណើថ្មីក៏ដោយ ក៏សហព្រះរាជអាជ្ញាមិនបានបង្ហាញនូវកាលៈទេសៈថ្មីឡើយ។ អង្គជំនុំជម្រះក៏មិនមានឃើញលក្ខខណ្ឌនៃវិធាន៣៥ត្រូវបានបំពេញឡើយ។ ហេតុដូច្នេះសំណើរបស់សហព្រះរាជអាជ្ញា ឯកសារ E293/1 ត្រូវច្រានចោល។

- **សំណើសុំរបស់សហព្រះរាជអាជ្ញាឱ្យធ្វើសេចក្ដីសន្និដ្ឋានផ្ទុយប្រឆាំងនឹងជនជាប់ចោទក្នុងករណីជនជាប់ចោទមិនឆ្លើយតបទៅនឹងសំណួរ**

  អង្គជំនុំជម្រះពិចារណាឃើញថា ការរំឭកដែលបានធ្វើចំពោះជនជាប់ចោទទាំងអស់កាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ និងការបញ្ជាក់សាជាថ្មីឡើងវិញ កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៣ គឺបានដោះស្រាយយ៉ាងគ្រប់គ្រាន់ចំពោះចំណុចសំខាន់នៅក្នុងសំណើជាសារធាតុ

របស់សហព្រះរាជអាជ្ញាហើយ។ ការរំឭកអំពីកាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ បានបញ្ជាក់ដោយយោងទៅរកយុត្តិសាស្ត្រអន្តរជាតិដែលពាក់ព័ន្ធថា ការសម្រេចជ្រើសរើសដោយខ្លួនឯងក្នុងការនៅស្ងៀមមិនឆ្លើយតបអាចត្រូវបានប្រើក្នុងការទាញចេញជាសេចក្តីសន្និដ្ឋានផ្ទុយ។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា សំណើទាំងអស់នេះត្រូវបានឆ្លើយតបរួចរាល់អស់ហើយ។ សហព្រះរាជអាជ្ញាបានស្នើសុំបន្ថែមដើម្បីថ្លែងនៅក្នុងសវនាការ ដោយមានវត្តមានរបស់ជនជាប់ចោទអំពីប្រធានបទ និងអង្គហេតុដែលខ្លួនចង់ចោទសួរទៅជនជាប់ចោទ។ អង្គជំនុំជម្រះពិចារណាឃើញថា សំណើនេះមិនមែនជាការចាំបាច់នោះទេ។ សហព្រះរាជអាជ្ញានឹងមានឱកាសសរសេរជាផ្នែកមួយនៃសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលនៅបណ្តាចំណុចទាំងឡាយដែលខ្លួនបានស្នើសុំឱ្យអង្គជំនុំជម្រះធ្វើការទាញសេចក្តីផ្ទុយនេះ។

- **សំណើសុំឱ្យកោះហៅសាក្សីដែលពាក់ព័ន្ធនឹងគោលនយោបាយដែលត្រូវបានចោទប្រកាន់ក្នុងការវាយប្រហារមន្ត្រីសាធារណរដ្ឋខ្មែរ**

មេធាវីការពារក្តី នួន ជា បានស្នើសុំឱ្យអង្គជំនុំជម្រះកោះហៅសាក្សីថ្មីជាង១០០នាក់ដែលបានឆ្លើយនៅក្នុងកំណត់ហេតុយកចម្លើយទាក់ទងនឹងការវាយប្រហារលើមន្ត្រីសាធារណរដ្ឋខ្មែរ។ សំណើនេះនិយាយច្រំដែល និងបានកែលម្អលើសំណើលើកមុនៗទាក់ទងនឹងភាពទទួលយកបាន មិនមានឱកាសសម្រាប់តទល់ទៅនឹងសេចក្តីថ្លែងការណ៍ ទាក់ទងនឹងបញ្ហាសំខាន់ទៅនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញា។ អង្គជំនុំជម្រះយល់ឃើញថា សំណើរបស់មេធាវីការពារក្តីខកខានមិនបានបំពេញលក្ខខណ្ឌសមហេតុផលក្នុងការបង្ហាញអំពីការរកឃើញសាក្សីថ្មីដែលត្រូវស្នើសុំកោះហៅឱ្យស្របតាមវិធាន ៨៧ អនុវិធាន៤នោះឡើយ។ លើសពីនេះទៅទៀត ចំពោះសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំឆ្លើយតបចំពោះសំណើនេះ អង្គជំនុំ-ជម្រះយល់ឃើញថា បញ្ហានេះទាក់ទងទៅនឹងភាពទទួលយកបាន និងតម្លៃនៃកំណត់ហេតុយកចម្លើយសាក្សីដែលត្រូវបានថ្លែងដោយសង្ខេបសព្វគ្រប់ហើយ។ អង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចលើបញ្ហានេះនាពេលឆាប់ៗខាងមុខនេះ។ សំណើដទៃទៀតនាពេលខាងមុខស្តីពីបញ្ហាទាំងនេះនឹងត្រូវចាត់ទុកថាច្រំដែល និងមិនទទួលយកបានឡើយ។ សំណើផ្ទាល់មាត់នេះត្រូវច្រានចោលដែលសំអាងហេតុលម្អិត និងមានចេញជាក្រោយ។

- **សំណើសុំរបស់មេធាវីការពារក្តី ខៀវ សំផន អំពីព័ត៌មានទាក់ទងនឹងសាក្សី នូ ម៉ុក**

ជាបឋម អង្គជំនុំជម្រះកត់សម្គាល់ថា អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ត្រូវបានសន្មត់ថាបំពេញមុខងាររបស់ខ្លួនដោយមិនលម្អៀង។ ភាគីនានាមានឱកាសស្រាវជ្រាវបញ្ហានានាទាក់ទងទៅនឹងការធ្វើទំនាក់ទំនងជាមួយអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងអំឡុងពេលសួរសាក្សីរូបនោះ។ លើសពីនេះទៅទៀត អង្គជំនុំជម្រះក៏បានទទួលនូវព័ត៌មានពាក់ព័ន្ធក្រៅផ្លូវការពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញហើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះសន្និដ្ឋានថាការស៊ើបអង្កេតស្របតាមវិធាន៣៥ ត្រូវច្រានចោល។ ប៉ុន្តែអង្គជំនុំជម្រះបង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញផ្តល់នូវព័ត៌មាននេះជាលាយលក្ខណ៍អក្សរផ្លូវការណ៍មកអង្គជំនុំ-ជម្រះក្នុងរយៈពេល២សប្តាហ៍។

- **សេចក្តីសម្រេចអំពីកាលបរិច្ឆេទនៃការដាក់សារណាបញ្ចប់ និងការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពីភាក្សាដេញដោល**

អង្គជំនុំជម្រះសាលាដំបូងសូមប្រកាសកាលបរិច្ឆេទបណ្តោះអាសន្នរបស់ខ្លួនដូចខាងក្រោមនេះ៖

សារណាបិទបញ្ចប់កិច្ចពិភាក្សាដេញដោលត្រូវដាក់ជូនយ៉ាងយូរបំផុតត្រឹមថ្ងៃទី១២ ខែកញ្ញា ឆ្នាំ ២០១៣ ដោយអាចដាក់ជាបឋមជាភាសាណាមួយរបស់ អ.វ.ត.ក ហើយដាក់ឯកសារបកប្រែតាមក្រោយ។ សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលនឹងត្រូវចាប់ផ្តើមធ្វើនៅថ្ងៃទី០៩ ខែតុលា ២០១៣ រហូតដល់បញ្ចប់នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ ដោយដំណើរការទាំងថ្ងៃសុក្រផងដែរ។ អង្គជំនុំជម្រះសម្រេចជ្រើសរើសយកថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៣ ជាថ្ងៃចាប់ផ្តើមសវនាការលើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល ដោយយោងទៅលើភាពស្មុគស្មាញក្នុងការរៀបចំកាលបរិច្ឆេទនៅក្នុងខែតុលានេះ ដែលមានថ្ងៃឈប់សម្រាកច្រើន។

- **សេចក្តីសម្រេចពីចំនួនទំព័រនៃសារណា បញ្ចប់ការពិភាក្សាដេញដោលដែលទាក់ទងនឹងសេចក្តីសម្រេចលើភស្តុតាងបន្ថែមដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះ**

ជាចុងក្រោយនេះពាក់ព័ន្ធទៅនឹងសារណាបញ្ចប់ការពិភាក្សាដេញដោល អង្គជំនុំជម្រះឯកភាពផ្តល់ជូនភាគីនីមួយៗ ចំនួន២៥ទំព័របន្ថែមទៀតដើម្បីឆ្លើយតបចំពោះភស្តុតាង

ឬឯកសារបន្ថែមដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង អនុលោមតាមសេចក្ដីសម្រេចស្ដាពរលើភស្តុតាងរបស់អង្គជំនុំជម្រះ។ ហេតុដូច្នេះសហព្រះរាជអាជ្ញាទទួលបាន ២២៥ទំព័រ សម្រាប់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល។ ជនជាប់ចោទនីមួយៗ ទទួលបាន ១២៥ទំព័រ ហើយដើមបណ្ដឹងរដ្ឋប្បវេណីទទួលបាន១០៥ទំព័រ ដោយមិនរាប់បញ្ចូលនូវសារណាស្ដីពីសំណង។

- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅមន្ទីរឃុំឃាំងវិញ។

| <u>ដីកាសម្រាប់ការលើកកាលវេលាសវនាការ</u> |
| --- |
| សវនាការនឹងបន្តទៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៣ ចាប់ផ្ដើមពីម៉ោង ៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣

ក្រឡាបញ្ជី ក្រឡាបញ្ជី

**សែ គុលធុឡា** **Roger PHILLIPS**